# ដៃជំនួយរបស់អេលី

*ដោយ រេបេកា រាយស៍ បើកឃិន*
*( ផ្អែកទៅលើដំណើររឿងពិត )*

« *There is plenty indeed for my two hands to do* » ( Children's Songbook *ទំព័រ ២៧២* ) ។



វាជាពេលព្រឹកថ្ងៃសៅរ៍ ហើយអេលីបានត្រៀមខ្លួនជាស្រេចនៅឯទីចាំគោលដៅ ដើម្បីការពារបាល់កុំឲ្យចូលទីគោលដៅ ។ គាត់បានលោតចុះឡើងប្រឹងអស់ពីសមត្ថភាពគាត់ដើម្បីការពារបាល់កុំឲ្យចូលក្នុងសំណាញ់របស់ទី ។ ប៉ុន្តែវាពិបាកណាស់ ! បន្ទាប់មក មុនពេលនឹងការប្រកួតនោះចប់ បាល់បានរអិលធ្លាក់ផុតពីដៃគាត់ ។ ក្រុមផ្សេងទៀតបានពិន្ទុ ! ក្រុមរបស់អេលីបានចាញ់ ។ គាត់សោកសៅខ្លាំងណាស់ ។

ថ្ងៃបន្ទាប់ទៀតនៅព្រះវិហារ អេលីបានដើរយឺតៗទៅថ្នាក់កុមាររបស់គាត់ទាំងមានអារម្មណ៍ស្រពាប់ស្រពោននៅឡើយ ។

អេលីបានឃើញមិត្តរបស់គាត់ខេតខាងក្រៅថ្នាក់ ។ ម៉ាក់របស់ខេតបានរុញរទេះពណ៌ផ្កាឈូករបស់ខេតទៅខាងក្នុង ។ គាត់បានឱបខេតមុននឹងចេញទៅថ្នាក់គាត់ ។

អេលីបាននិយាយថា « សួស្តី ខេត » ។

ខេតមិនអាចឆ្លើយតប ឬគ្រវីដៃត្រឡប់វិញបានទេ ប៉ុន្តែនាងតែងតែសម្លឹងទៅចំភ្នែករបស់អេលី ដើម្បីឲ្យគាត់ដឹងថានាងបានឮគាត់ ។

ធម្មតាខេតញញឹមពេលអេលីនិយាយសួស្តី ប៉ុន្តែថ្ងៃនេះអត់ទេ ។ *តើខេតសោកសៅឬ ?* អេលីបានឆ្ងល់ ។ *ខ្ញុំ ដឹងថាវាមានអារម្មណ៍យ៉ាងណា* ។ គាត់នៅតែមានអារម្មណ៍សោកសៅដែលគាត់មិនអាចការពារបាល់ពីក្រុមមួយទៀតបាន ។

អេលីបានអង្គុយក្បែរចន និងម៉ាយេល ពេលសិស្ទើរយ៉ង់បានចាប់ផ្តើមថ្នាក់ ។ បន្ទាប់មកខេតបានថ្ងូរ ។ ជួនកាលវាពិបាកសម្រាប់ខេតដើម្បីអង្គុយនៅស្ងៀម ដោយសាររាងកាយនាងឈឺចាប់ ។

« ខេត តើប្អូនឈឺឬថ្ងៃនេះ ? » សិស្ទើរយ៉ង់បានសួរ ។

ខេតបានចាប់ផ្តើមយំ ។

សិស្ទើរយ៉ង់បាននិយាយថា « ប្រហែលជាចម្រៀងថ្នាក់កុមារមួយនឹងជួយ ។

កុមារក្នុងថ្នាក់បានចាប់ផ្តើមច្រៀង ។ ខេតចូលចិត្តដន្ត្រី ។ ធម្មតានាងច្រៀងតាមដោយធ្វើជាសំឡេងសប្បាយៗ ។ ប៉ុន្តែថ្ងៃនេះ ខេតគ្រាន់តែយំប៉ុណ្ណោះ ។

*តើយើងអាចជួយខេតឲ្យមានអារម្មណ៍ប្រសើរឡើងយ៉ាងដូចម្តេច ?* អេលីបានឆ្ងល់ ។

បន្ទាប់មកមានគំនិតមួយបានផុសឡើង ។ « ខ្ញុំដឹង ! » អេលីបានប្រាប់សិស្ទើរយ៉ង់ ។ « ខ្ញុំនឹងរុញរទេះរបស់ខេតបន្តិច » ។

អេលីបានឃើញម៉ាក់របស់ខេតរុញរទេះនាងថ្នមៗ ពេលខេតត្រូវការមានអារម្មណ៍ប្រសើរឡើង ។ គាត់បានប្រញាប់ដើរទៅកាន់ខេត ហើយបានចាប់ផ្តើមរុញរទេះនាងយឺតៗទៅវិញទៅមក ។

ខេតបានឈប់យំ ។

ចនបានសួរ « តើខ្ញុំសូមធ្វើដែរបានទេ ? »

« ខ្ញុំដែរ ! » ម៉ាយេលបាននិយាយ ។

កាលដែលសិស្ទើរយ៉ង់បានបង្រៀនមេរៀន អេលី និងមិត្តរបស់គាត់បានដាក់វេនគ្នារុញរទេះរបស់ខេត ។ ខេតបានញញឹម ។ បន្ទប់ទាំងមូលហាក់ដូចជាមានពន្លឺចែងចាំងជាងមុន ។

ទម្រាំដល់ថ្នាក់បញ្ចប់ គ្រប់គ្នាញញឹម ។

អេលីបាននិយាយថា « ការជួយខេតធ្វើឲ្យខ្ញុំសប្បាយចិត្ត » ។

សិស្ទើរយ៉ង់បាននិយាយថា « ខ្ញុំរីករាយណាស់ ។ « វាធ្វើឲ្យព្រះវរបិតាសួគ៌សប្បាយព្រះទ័យផងដែរ ។ ទ្រង់ស្រឡាញ់ខេត ហើយមានព្រះទ័យចង់ឲ្យនាងមានអារម្មណ៍ប្រសើរឡើង ។ ជួនកាលយើងបានធ្វើជាអ្នកជួយរបស់ទ្រង់ » ។



អេលីបានសម្លឹងទៅខេត ។ គាត់បានប្រាប់នាងថា « ឯងជួយខ្ញុំផងដែរ ។ រាល់ពេលដែលឯងញញឹម » ។

ខេតបានញញឹម ។

ពេលអេលីបានត្រឡប់ទៅផ្ទះពីព្រះវិហារវិញ គាត់បានមានអារម្មណ៍កក់ក្តៅមួយដូចជាទីវាលបាល់ទាត់នៅក្រោមកម្តៅថ្ងៃខែប្រាំងអញ្ចឹង ។ គាត់បានគិតថា *ប្រហែលជាខ្ញុំពុំអាចចាប់បាល់បានទាំងអស់ទេ ។ ប៉ុន្តែខ្ញុំនៅតែអាចប្រើដៃខ្ញុំជួយមនុស្សបាន ។* ●

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*



« តាមរយៈសេចក្តីសប្បុរស និងការបម្រើចេញពីដួងចិត្តរបស់យើង យើងអាចធ្វើមិត្តជាមួយអស់អ្នកដែលយើងបម្រើបាន » ។

ប្រធាន អិម រ័សុល បាឡឺដ ប្រធានស្តីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Finding Joy through Loving Service » *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៤៨ ។

រចនារូបភាពដោយ មេលីស្សា មែនវីល